# និន្នាការសេដ្ឋកិច្ចសង្គម

## Socio-Economic Trends

### ខែវិច្ឆិកា-ធ្នូ ឆ្នាំ២០១៩ /November-December 2019

## មាតិកា


| | ទំព័រ |
|---|---|
| **ខ្លឹមសារសង្ខេប/Executive summary** | **១** |
| **១. និន្នាការសេដ្ឋកិច្ចកម្ពុជា/Cambodia economic trends** | **៣** |
| ១.១. សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់/Consumer price index | ៣ |
| ១.២. វិស័យហិរញ្ញវត្ថុ/Finance | ៤ |
| ១.៣. វិស័យពាណិជ្ជកម្ម/Trade | ៥ |
| ១.៤. ការអនុវត្តថវិកា/Budget execution | ៩ |
| ១.៥. វិស័យវិនិយោគឯកជន/Private investment | ១០ |
| ១.៦. វិស័យទេសចរណ៍/Tourism | ១២ |
| ១.៧. វិស័យសំណង់/Construction | ១៤ |
| **២. និន្នាការថ្លៃទំនិញសំខាន់ៗ /Commodity prices** | **១៥** |
| ២.១. ថ្លៃប្រេងឆៅ (Crude oil price: Brent, WTI, Dubai) | ១៥ |
| ២.២. ថ្លៃអង្ករ (Rice price: 5%, 25%, 100% broken) | ១៦ |
| ២.៣. ថ្លៃកៅស៊ូ (Rubber price: TSR20, SGP/MYS) | ១៧ |
| **៣. ឧបសម្ព័ន្ធ** | **១៨** |

## ខ្លឹមសារសង្ខេប / Executive summary

**១.** ក្នុងឆ្នាំ២០១៩នេះ កម្ពុជាទទួលបានភ្ញៀវទេសចរអន្តរជាតិសរុបប្រមាណ ៦,៦ លាននាក់ បានកើនឡើង ៦,៦% ធៀបនឹងឆ្នាំមុន។ ធៀបនឹងភ្ញៀវទេសចរអន្តរជាតិសរុប ភ្ញៀវទេសចរចិនមាន ៣៥,៧% គឺបានកើនឡើង ១៦,៧%, វៀតណាម ១៣,៨% បានកើនឡើង ១៣,៦%, ថៃ ៧,១% បានកើនឡើង ២២% និងបន្តបន្ទាប់រួមមាន ឡាវ, កូរ៉េខាង-ត្បូង, អាមេរិក, ជប៉ុន, ម៉ាឡេស៊ី, បារាំង និងអង់គ្លេស។ ក្នុងកំណើនសរុប ៦,៦%នេះ ភ្ញៀវទេសចរចិនបានចូលរួមចំណែកកំណើន (contribution to growth) ៥,៤%។ ភ្ញៀវទេសចរអន្តរជាតិតាមតំបន់គោលដៅសំខាន់ៗក្រៅពីរមណីយដ្ឋានអង្គរ នៅតែរក្សាបានកំណើន ប៉ុន្តែ ភ្ញៀវអន្តរជាតិមកទស្សនារមណីយដ្ឋានអង្គរ[1] បានធ្លាក់ចុះខ្លាំងក្នុងអត្រាអវិជ្ជមាន -១៤%៨, ដែលបណ្តាលឱ្យចំណូលពីការលក់សំបុត្រចូលទស្សនាបានធ្លាក់ចុះ -១៥។ ការធ្លាក់ចុះនៃភ្ញៀវទេសចរអន្តរជាតិចូលទស្សនារមណីយដ្ឋានអង្គរអាចជាសញ្ញាមិនល្អដល់ស្ថិរភាព% កំណើននៃវិស័យទេសចរណ៍ឆ្នាំ២០២០។ **រាជរដ្ឋាភិបាលគួរផ្តោតការយកចិត្តទុកដាក់លើយន្តការទាក់ទាញភ្ញៀវទេសចរមិនមែនចិន និងភ្ញៀវទេសចរក្នុងស្រុកឱ្យកាន់តែខ្លាំងបន្ថែមទៀត ដើម្បីកាត់បន្ថយហានិភ័យលើភាពពឹងផ្អែកខ្លាំងលើភ្ញៀវទេសចរចិន ខណៈពេលដែល កំណើនសេដ្ឋកិច្ចចិននឹងថមថយនៅឆ្នាំ២០២០[2], ការផ្ទុះនូវវីរ៉ុសក្លូរណានាដើមឆ្នាំ២០២០, និងការធ្លាក់ចុះ[3]នៃកំណើនភ្ញៀវទេសចរ ចូលតាមច្រកកងកេងចាប់តាំងពីខែកញ្ញា ដល់ ខែធ្នូឆ្នាំ២០១៩ ក្នុងអត្រា -២៤%, -១២%, -៣៥% និង -១៤%។**

**២.** ក្នុងឆ្នាំ២០១៩នេះ គម្រោងវិនិយោគឯកជនសរុប[4] មានចំនួន **១៩៧** គម្រោង បានកើនឡើង ៤៩ គម្រោង និងមានទុនវិនិយោគប្រមាណ **៨ ១៦០** លានដុល្លារ កើនឡើង ៤០,៦% ធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន។ ក្នុងចំណោមគម្រោងទាំង ១៩៧ នេះ, ១៦២ គម្រោង ជាវិនិយោគក្នុងវិស័យឧស្សាហកម្ម(៤៩ លើរោងចក្រកាបូប, ៥១ លើរោងចក្រកាត់ដេរសម្លៀកបំពាក់) ដែលជាសញ្ញាបង្ហាញថាការវិនិយោគក្នុងវិស័យកាត់ដេរ នៅតែបន្តកើនឡើង និងរំពឹងថាវិស័យនេះអាចរក្សាកំណើនបន្តទៀតនៅឆ្នាំ២០២០នេះ។ បន្ថែមពីនេះ ក៏មានគម្រោងវិនិយោគផ្នែកថាមពល ដូចជា ថាមពល (Grid substation & Transmission Line), ថាមពលសូឡា, និង បន្ទះសូឡា ដែលនឹងចូលរួមចំណែកក្នុងការធ្វើពិពិធកម្មប្រភពថាមពលកម្ពុជាសម្រាប់ផ្គត់ផ្គង់តម្រូវការក្នុងស្រុកដែលមានតម្រូវការកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំសម្រាប់រោងចក្រឧស្សាហកម្ម, អាជីវកម្ម និង គ្រួសារ។ ទោះបីជាមានកំណើនវិនិយោគថ្មីៗលើបន្ទះសូឡា, រោងចក្រ តម្លើងរថយន្ត, Cosmetic Products, Mechanic Assembly និង ផលិតកម្មទាន (candle), ការធ្វើពិពិធកម្ម វិស័យឧស្សាហកម្មនៅក្រៅតំបន់សេដ្ឋកិច្ចពិសេសនៅតែមានកម្រិតខ្លាំង ដោយសារ វិស័យនេះនៅតែពឹងផ្អែកខ្លាំងលើការវិនិយោគលើរោងចក្រ និងរោងចក្រកាត់ដេរសម្លៀកបំពាក់។

៣. ក្នុងឆ្នាំ២០១៩ ការនាំចេញទំនិញ[5]របស់កម្ពុជាសម្រេចបានក្នុងទំហំទឹកប្រាក់សរុប ១៤ ៥២៧ លានដុល្លារ )៥៤,២% ធៀបនឹងផសស[6] (បានកើនឡើង ១៤,៩ %ធៀបរយៈនឹងឆ្នាំ២០១៨ ដែលមានអត្រា ១៣%៤,។ ទោះជាយ៉ាងនេះក្តី ទំហំទឹកប្រាក់

---

[1] ទិន្នន័យផ្លូវការពីគ្រឹះស្ថានអង្គរ

[2] របាយការណ៍ World Economic Outlook របស់ IMF ក្នុងខែមករា ឆ្នាំ២០២០

[3] ការគណនាយកខែសីហាជាគោលដោយយកខែទី n ធៀបនឹងខែទី n-1

[4] គម្រោងវិនិយោគឯកជនក្រៅតំបន់សេដ្ឋកិច្ចពិសេស ដែលទទួលបានការអនុញ្ញាតដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

[5] ទិន្នន័យផ្លូវការបឋមពីអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា (Admin Data)

[6] ផសស (GDP at current price Million US$) = ២៦ ៧៨៦ លានដុល្លារ÷ យោងតាមតារាងMacro-framework ថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៩។

នាំចេញផលិតផលសំខាន់ៗមានការថមថយកំណើន ក្នុងនោះរួមមាន ផលិតផលកាត់ដេរនិងស្បែកជើង អង្ករ និងកង់។,ជារួម ស្ថានភាពការនាំចេញរបស់កម្ពុជានៅក្នុងឆ្នាំ ២០១៩ នៅតែរក្សាបានកំណើនល្អប្រសើរ ដែលគាំទ្រមួយផ្នែកធំដោយកំណើនខ្ពស់នៃការនាំចេញទៅកាន់ទីផ្សារសហរដ្ឋអាមេរិក ដែលបានចូលរួមចំណែកកំណើន រហូតដល់១១ ។(%៩,១៤) នៃកំណើនការនាំចេញសរុប %១, *ក៏ប៉ុន្តែ ជាការសន្និដ្ឋាន ទំហំការនាំចេញរបស់កម្ពុជានឹងអាចថមថយបន្តិចនៅក្នុងត្រីមាសទី១ និងត្រីមាសទី២ ក្នុងឆ្នាំ២០២០ ខាងមុខនេះ ដោយសារ ១)ការប្រឈមនឹងការលុបចោលនូវប្រព័ន្ធអនុគ្រោះពន្ធ EBA ដោយសហភាពអឺរ៉ុប និង ២)ការរីករាលដាលនៃ Corona Virus ដែលអាចបណ្តាលឱ្យសេដ្ឋកិច្ចចិន និងសកលមានកំណើនថមថយ ដោយសារការប៉ះពាល់យ៉ាងអវិជ្ជមានដល់ខ្សែច្រវ៉ាក់ផលិតកម្មសកល ដែលធ្វើឱ្យការផ្គត់ផ្គង់ទាំងវត្ថុធាតុដើម និងផលិតផលសម្រេច ដល់ប្រទេសជាច្រើននៅលើពិភពលោក រួមទាំងកម្ពុជាផងដែរមានការផ្អាកជាបណ្តោះអាសន្ន។* ចំណែកឯ ការនាំចូលមកកម្ពុជាសម្រេចបានទឹកប្រាក់សរុបចំនួន ២០ ៥២០ លានដុល្លារ )៧៦ធៀបនឹង %៦,ផសសបាន (កើនឡើង ២១,៦ %ទាបជាងកំណើនក្នុងឆ្នាំមុន ដែលមានអត្រា ២៤។%០, កំណើនថមថយនេះ គឺបណ្តាលមកពីការបន្តកំណើនទាបនៃការនាំចូលផលិតផលវាយនភណ្ឌ ខណៈពេលដែលការនាំ (ពិសេសក្រណាត់) ចូលផលិតផលសំខាន់ផ្សេងៗទៀតនៅតែបន្តរក្សាបានកំណើនរឹងមាំ។ កំណើននាំចូលនេះ អាចបង្ហាញអំពី ១)កំណើនតម្រូវការប្រើប្រាស់ក្នុងស្រុកទាំង consumption goods និង luxurious goods និង (យានយន្ត) ២)ការរីកលូតលាស់នៃសកម្មភាពសេដ្ឋកិច្ចក្នុងស្រុក ជាពិសេសពាក់ព័ន្ធនឹងសកម្មភាពផលិតកម្មសម្រាប់ការនាំចេញនិងផគត់ផ្គង់ក្នុងស្រុក និងកំណើនវិនិយោគលើ វិស័យគន្លឹះ ជាពិសេស សំណង់។

៤. ក្នុងឆ្នាំ២០១៩ សំណើសុំសាងសង់សរុបមានចំនួន ៤ ៧៩៣ គម្រោង បានកើនឡើង ១ ៤៩៩ គម្រោង ក្នុងផ្ទៃក្រឡា ២៣,២ លានម៉ែត្រការ៉េ បានកើនឡើង ៨៤,៦% និងមានតម្លៃ ១១,៤ ប៊ីលានដុល្លារ បានកើនឡើង ៩៨,៣% ធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន។ ការសម្រេចបានកំណើនខ្ពស់នេះ ដោយសារកំណើននៃប្រភេទសំណង់ឧស្សាហកម្ម និងលំនៅដ្ឋាន ហើយកំណើននេះ ក៏ត្រូវបានឆ្លុះបញ្ចាំងតាមរយៈការនាំចូលសម្ភារសំណង់ក្នុងឆ្នាំ២០១៩នេះ។

៥. ក្នុងឆ្នាំ២០១៩[7] រដ្ឋបាលថ្នាក់ជាតិប្រមូលចំណូលក្នុងស្រុកសរុបបានចំនួន **២៤ ៧៤៩,៥** ប៊ីលានរៀល ឬស្មើនឹង **១២៥,១%** នៃច្បាប់ឆ្នាំ២០១៩ បានកើនឡើង **២១,៧%** ធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន។ ទន្ទឹមនេះ រដ្ឋបាលថ្នាក់ជាតិអនុវត្តចំណាយសរុបបានចំនួន **២២ ២១១,២** ប៊ីលានរៀល ឬស្មើនឹង **៨៩,៤%** នៃច្បាប់២០១៩ បានថមថយប្រមាណ **0,9%**។ ជាលទ្ធផលគិតត្រឹមខែធ្នូឆ្នាំ២០១៩ តុល្យភាពថវិកាចរន្តមានអតិរេកសាច់ប្រាក់ចំនួន **៩ ៣២៨,៤** ប៊ីលានរៀល និងតុល្យភាពថវិកាសរុបមានអតិរេកសាច់ប្រាក់ចំនួន **២ ៥៣៨,៣** ប៊ីលានរៀល។ អតិរេកចរន្តនេះ អាចជាបច្ច័យល្អសម្រាប់ការសន្សំថវិកាជាតិ និងអាចប្រើប្រាស់ជា Stimulus Package ក្នុងករណីចាំបាច់ណាមួយ។

**៦**. នៅខែធ្នូ ឆ្នាំ២០១៩នេះ[8] សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់និងសេវាកម្មនៅរាជធានីភ្នំពេញ *បានកើនឡើងក្នុងអត្រា ០%៨, ធៀបនឹងខែមុន និង ៣ធៀប %១,នឹងខែដូចគ្នាឆ្នាំមុន។* តាមការសង្កេត អត្រាអតិផរណាមធ្យមប្រចាំឆ្នាំ (year average) មានការថមថយកំណើនពី ២ក្នុងឆ្នាំ %៥, ២០១៨ មកត្រឹម ១%៩, ក្នុងឆ្នាំ ២០១៩។

[7] ទិន្នន័យផ្លូវការបឋមពីធនាគារជាតិ គិតត្រឹមថ្ងៃទី២ ខែមករា ឆ្នាំ២០២០

[8] ទិន្នន័យផ្លូវការពីវិទ្យាស្ថានជាតិស្ថិតិ

# ៣. ឧបសម្ព័ន្ធ

## ១. និន្នាការសេដ្ឋកិច្ចកម្ពុជា / Cambodia economic trends

### ១.១. ស្ថានភាពសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ / Consumer price index

អត្រាអតិផរណា មានស្ថិរភាព ដោយការថមថយសន្ទស្សន៍ថ្លៃម្ហូបអាហារ និងថយចុះសន្ទស្សន៍ថ្លៃប្រេងឥន្ធនៈ (កំណើនមធ្យមប្រចាំឆ្នាំ)



ប្រភព÷ វិទ្យាស្ថានជាតិស្ថិតិ

### ១.៣. វិស័យពាណិជ្ជកម្ម / Trades







ប្រភព÷ GDCE, MEF



















ប្រភព÷ GDCE, MEF
















ប្រភព៖ GDCE, MEF

## ១.៤. ការអនុវត្តថវិការដ្ឋ / Budget execution







ប្រភព៖ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## ១.៥. ស្ថានភាពវិនិយោគ / Investment







ប្រភព÷ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

## ១.៦. ស្ថានភាពទេសចរណ៍ / Tourism




ប្រភព÷ ក្រសួងទេសចរណ៍

## ១.៧. ស្ថានភាពសំណង់ / Construction




ប្រភព÷ ក្រសួងដែនដី នគរូបនីយកម្ម និងសំណង់

## ២. និន្នាការថ្លៃទំនិញសំខាន់ៗ / Commodity prices




ប្រភព៖ ក្រសួងពាណិជ្ជកម្ម




ប្រភព៖ ធនាគារពិភពលោក (Pink Sheet)




ប្រភព÷ ក្រសួងពាណិជ្ជកម្ម




ប្រភព÷ ធនាគារពិភពលោក (Pink Sheet)




ប្រភព÷ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ




ប្រភព÷ Association of Natural Rubber Producing Countries (ANRPC)

**<u>កំណត់សម្គាល់</u>**

កៅស៊ូ÷

- កៅស៊ូ TSR20: ឬហៅថាកៅស៊ូស្តង់ដារលេខ២០ រួមមានកៅស៊ូ SIR20, SMR20 និង STR20 គឺសំដៅលើកៅស៊ូធម្មជាតិដែលមានសារធាតុផ្សេងៗទៀត២០%។ កៅស៊ូធម្មជាតិមានច្រើនប្រភេទ ក្នុងនោះកៅស៊ូដែលមានតម្រូវការប្រើប្រាស់ច្រើនជាងគេគឺកៅស៊ូស្តង់ដារ (កៅស៊ូដុំ) និងកៅស៊ូបន្ទះ។ កៅស៊ូ TSR20 ជាប្រភេទកៅស៊ូដែលបានកែច្នៃក្នុងកម្រិតខ្ពស់ ប្រើប្រាស់សម្រាប់ ផលិតកម្មកង់ឡាន បំពង់ទីបជ័រ កម្រាលជ័រ ស្បែកជើងនិងអាវភ្លៀងជាដើម។ កៅស៊ូប្រភេទនេះមានកម្រិតស្អិតទាប ហើយងាយលាយបញ្ចូល ជាមួយសារធាតុដទៃ ដែលធ្វើឱ្យផលិតផលផលិតចេញពីកៅស៊ូនេះមានភាពរឹងមាំ ធន់និងមិនងាយសឹករិចរិល។ ប្រទេសសំខាន់ៗដែលផលិតកៅស៊ូប្រភេទនេះគឺម៉ាឡេស៊ី ថៃ ឥណ្ឌូណេស៊ី វៀតណាម និងចិន។
- កៅស៊ូ RSS (Ribbed Smoked Sheets) បែងចែកជា៦ប្រភេទគឺ ប្រភេទលេខ 1, 2, 3, 4, 5 និងប្រភេទពិសេស មានពណ៌លឿងនិងវេចខ្ចប់ជាបន្ទះ។ កៅស៊ូប្រភេទ RSS3 ច្រើនផលិតនៅប្រទេសថៃ ឥណ្ឌា និងឥណ្ឌូណេស៊ី ប្រើប្រាស់ជាវត្ថុធាតុ សម្រាប់ផលិតសំបកកង់រថយន្ត បំពង់ទីបជ័រ និងស្បែកជើង។ កៅស៊ូប្រភេទនេះប្រើប្រាស់ក្នុងឧស្សាហកម្មផលិតសំបកកង់ រថយន្ត និងដែលជាធាតុផ្សំលើស 50% នៃផលិតផល។

ប្រេងឆៅ÷

ប្រេងឆៅ Brent, WTI និង Dubai ជាប្រភេទប្រេងឆៅធុនស្រាល (Light Crude Oil) ដែលមានការទិញលក់ច្រើនជាងគេ និងជាថ្លៃមូលដ្ឋានក្នុងការទិញលក់កិច្ចសន្យាអនាគត (Future Contract)។ ប្រេងឆៅលើទីផ្សារអន្តរជាតិមានលក្ខណៈខុសគ្នា ទៅតាមប្រភេទដូចជា÷ ប្រភេទប្រេង Brent ច្រើនផលិតនៅតំបន់សមុទ្រអាត្លង់ទិចខាងជើង, ប្រភេទប្រេងរបស់អាមេរិក WTI (West Texas Intermediate) និងប្រភេទប្រេងរបស់អារ៉ាប់ប៊ីសាអ៊ូឌីត Dubai។ ប្រភេទប្រេងឆៅទាំងបីមានលក្ខណៈ ខុសគ្នាទៅតាមកម្រិតភាពស្រាល ហើយប្រភេទប្រេងឆៅដែលមានភាពស្រាលជាងគេអាចចម្រាញ់ជាប្រេងឥន្ធនៈបានច្រើន។ API Gravity ត្រូវបានគេប្រើប្រាស់វាស់វែងភាពស្រាលនៃប្រភេទប្រេងឆៅនីមួយៗ។ ប្រភេទប្រេងដែលមានកម្រិត API Gravity កាន់តែខ្ពស់គឺជាប្រភេទប្រេងដែលកាន់តែស្រាល និងអាចចម្រាញ់ជាប្រេងឥន្ធនៈបានច្រើន។

- WTI 40$^{o}$ API
- Brent 38$^{o}$ API
- Dubai 32$^{o}$ API

រៀបចំដោយ

នាយកដ្ឋានស្ថិតិនិងវិភាគសេដ្ឋកិច្ច

អគ្គនាយកដ្ឋានគោលនយោបាយ

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ព័ត៌មានផ្សេងៗ សូមទាក់ទងក្រុមការងារ

ទូរស័ព្ទលេខ÷ ០២៣ ៤២៧ ៩១៣, ០៩៨  ២២ ៨៤ ៩៤

ម៉ោងធ្វើការ÷ ៨:០០ ដល់ ១២:០០ព្រឹក និង ២:០០ ដល់ ៥:០០រសៀល